ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០៦០......អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- យោងតាមតម្រូវការចាំបាច់របស់និយ័តករធានារ៉ាប់រងកម្ពុជា

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌនិងនីតិវិធីក្នុងការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងសកម្មភាពអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រង គណនាបុព្វលាភធានារ៉ាប់រង និងគ្រប់គ្រងសំណងធានារ៉ាប់រង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់សកម្មភាពអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រង គណនាបុព្វលាភធានារ៉ាប់រង និងគ្រប់គ្រងសំណងធានារ៉ាប់រងទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ មាននិយមន័យដូចតទៅ៖

- **អាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង** សំដៅដល់អាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រង អាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង និងអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រង។
- **ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង** សំដៅដល់នីតិបុគ្គលឯករាជ្យដែលមានភារកិច្ចត្រួតពិនិត្យផ្ទៀងផ្ទាត់ វាយតម្លៃការខូចខាតពេលមានហានិភ័យធានារ៉ាប់រងកើតឡើង និងកំណត់ចេញនូវឯកសារសម្រាប់ជាមូលដ្ឋានឱ្យក្រុមហ៊ុនធានារ៉ាប់រងដោះស្រាយទូទាត់សំណង។ ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងធ្វើសកម្មភាពដោយទទួលថ្លៃឈ្នួលពិនិត្យពីក្រុមហ៊ុនធានារ៉ាប់រង។
- **ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនវិជ្ជាជីវៈដែលមានជំនាញវិភាគ និងគណនាហានិភ័យធានារ៉ាប់រង ដើម្បីកំណត់អត្រាបុព្វលាភធានារ៉ាប់រង។
- **ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនវិជ្ជាជីវៈដែលមានជំនាញគ្រប់គ្រងចាត់ចែង ដោះស្រាយសំណងធានារ៉ាប់រងជំនួសឱ្យក្រុមហ៊ុនធានារ៉ាប់រង ឬគម្រោងគ្រប់គ្រងអត្ថប្រយោជន៍របស់នីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដោយទទួលបានកម្រៃសេវាពីក្រុមហ៊ុនធានារ៉ាប់រង ឬនីតិបុគ្គលប្រតិស្រុតទាំងនោះ តាមកិច្ចព្រមព្រៀង។
- **សាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស** សំដៅដល់សាខារបស់ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេសដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃហើយមានទីតាំងធ្វើ

ពាណិជ្ជកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។ សាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស គឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

- **សាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស** សំដៅដល់សាខារបស់ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេសដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃហើយមានទីតាំងធ្វើពាណិជ្ជកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។ សាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេសគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។
- **សាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស** សំដៅដល់សាខារបស់ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃហើយមានទីតាំងធ្វើពាណិជ្ជកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។ សាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។
- **នីតិបុគ្គលប្រូតិស្រូត** សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **អគ្គនាយក** សំដៅដល់បុគ្គលមានឋានៈខ្ពស់បំផុតក្នុងកម្រិតប្រតិបត្តិរបស់ក្រុមហ៊ុន ដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងកិច្ចប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន។
- **បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំសេវារដ្ឋបាលពីនិយ័តករធានារ៉ាប់រងកម្ពុជា។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**ប្រការ៤ .-**

និយ័តករធានារ៉ាប់រងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា “**ន.ធ.ក.**” មានសមត្ថកិច្ចក្នុងការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនវាយតម្លៃហានិភ័យធានា-រ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៣

## លក្ខខណ្ឌ និងនីតិវិធី

## នៃការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង

### ផ្នែកទី១

### ការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស

**ប្រការ៥.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង មក **ន.ធ.ក.** ដោយបំពេញលក្ខខណ្ឌគោលដូចខាងក្រោមៈ

- ជានីតិបុគ្គលប្រតិស្រុត
- មានដើមទុនអប្បបរមាចំនួន ៨០ ០០០ ០០០(ប៉ែតសិបលាន) រៀល ក្នុងនោះប្រាក់តម្កល់ធានាអាជីវកម្មមានចំនួន ៤០ ០០០ ០០០(សែសិបលាន) រៀល
- មានការធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០(ពីរប៊ីលាន) រៀល
- មានបុគ្គលវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រងយ៉ាងតិច ១ (មួយ) រូប។

**ប្រការ៦.-**

ជាដំណាក់កាលដំបូង មុននឹងស្នើសុំអាជ្ញាបណ្ណ បុគ្គលត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោមៈ

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- ឯកសារអំពីការសិក្សាសមិទ្ធិលទ្ធភាពនៃទីផ្សារវាយតម្លៃហានិភ័យធានារ៉ាប់រងកម្ពុជា
- ផែនការអាជីវកម្មរយៈពេល ៥ (ប្រាំ) ឆ្នាំ
- សេចក្តីព្រាងលក្ខន្តិកៈក្រុមហ៊ុនដែលនឹងបង្កើត
- ឯកសារថតចម្លងបញ្ជាក់អត្តសញ្ញាណរបស់ភាគទុនិកៈ

- សម្រាប់ភាគទុនិកជារូបវន្តបុគ្គល ត្រូវផ្តល់អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន
- សម្រាប់ភាគទុនិកជានីតិបុគ្គល ត្រូវផ្តល់ឯកសារគតិយុត្តអំពីអាជីវកម្ម និងអាសយដ្ឋានទីស្នាក់ការកណ្តាល

- ឯកសារថតចម្លងបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល និងអភិបាល រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបស្តីពីបទពិសោធការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រ
- ឯកសារបញ្ជាក់នាមករណ៍ក្រុមហ៊ុនបម្រុងទុក នៅក្រសួងពាណិជ្ជកម្ម
- ក្នុងករណីជាបុត្រសម្ព័ន្ធក្រុមហ៊ុន ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ត្រូវផ្តល់ឯកសារបន្ថែមដូចខាងក្រោម៖
  - លិខិតអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម ឱ្យប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ថតចម្លងបញ្ជាក់ដោយសារការី
  - សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម អនុញ្ញាតឱ្យប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - ឯកសារអំពីប្រវត្តិសង្ខេប និងរចនាសម្ព័ន្ធនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - ឯកសារអំពីចំណាត់ថ្នាក់របស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ដោយមានការវាយតម្លៃរបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ជាអន្តរជាតិ (ប្រសិនបើមាន)
  - របាយការណ៍ស្តីពីលទ្ធផលត្រួតពិនិត្យចុងក្រោយរបស់និយ័តករនៃប្រទេសដើម ជាច្បាប់ថតចម្លង (ប្រសិនបើមាន)។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។ **ន.ធ.ក.** ផ្តល់លិខិតអនុញ្ញាតជាគោលការណ៍នេះ ជូនបុគ្គលស្នើសុំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងបន្តនីតិវិធីផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៧.-**

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រង ជា

ក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស និងបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- សាលាកបត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញនិងដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល តាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា
- លិខិតអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីរចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រង ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីគណនីរបស់ក្រុមហ៊ុននៅធនាគារដែលបញ្ជាក់ចំនួនដើមទុនអប្បបរមាដែលមានចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារបញ្ជាក់ចំនួនប្រាក់តម្កល់ធានាអាជីវកម្មដែលមានចំនួន ៤០ ០០០ ០០០ (សែសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០ (ពីរប៊ីលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ ជាច្បាប់ថតចម្លងដោយធ្វើនីត្យានុកូលកម្មពីអាជ្ញាធរដែនដី
- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងគុណវុឌ្ឍិរួមមាន អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ប្រវត្តិរូបសង្ខេបដោយមានបញ្ជាក់ពីបទពិសោធការងារនិងការសិក្សា និងវិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ ហានិភ័យធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបអំពីបទពិសោធការងារនិងការសិក្សាដោយភ្ជាប់សញ្ញាបត្រ
- លិខិតឬព្រឹត្តិបត្រថ្កោលទោសរបស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក ជាច្បាប់ដើមឬថតចម្លងបញ្ជាក់ដោយសារការី
- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រង ដោយភ្ជាប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិ រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន ប្រវត្តិរូបសង្ខេប និងវិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់អាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៨.-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង មក **ន.ធ.ក.** ឱ្យបានមុនរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ នៃកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រងដែលត្រូវបន្តសុពលភាព ជាច្បាប់ដើម
- ផែនការអាជីវកម្មសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំបន្ទាប់ ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០ (ពីរប៊ីលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ឆ្នាំចុងក្រោយ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចបន្តសុពលភាព

អាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៩ .-**

ក្នុងករណីក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេសមិនបានស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេសនោះត្រូវចាត់ទុកថាប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រងដោយគ្មានអាជ្ញាបណ្ណ។

**ប្រការ១០ .-**

អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស មានសុពលភាព ៥ (ប្រាំ) ឆ្នាំ។ អាជ្ញាបណ្ណនេះមិនអាចផ្ទេរ ឬលក់បានឡើយ។

**ប្រការ១១ .-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេសត្រូវបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រងឱ្យទាន់ពេលវេលាមុនផុតសុពលភាពវិញ្ញាបនបត្រ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រង។

## ផ្នែកទី២

## ការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស

**ប្រការ១២ .-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង មក **ន.ធ.ក.** ដោយបំពេញលក្ខខណ្ឌគោលដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- មានដើមទុនអប្បបរមាចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល ក្នុងនោះប្រាក់តម្កល់ធានាអាជីវកម្មមានចំនួន ៤០ ០០០ ០០០ (សែសិបលាន) រៀល

- មានការធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ៤ ០០០ ០០០ ០០០ (បួនប៊ីលាន) រៀល
- មានបុគ្គលវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងយ៉ាងតិច ១ (មួយ) រូប។

**ប្រការ១៣ -**

ជាដំណាក់កាលដំបូង មុននឹងស្នើសុំអាជ្ញាបណ្ណ បុគ្គលត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- ឯកសារអំពីការសិក្សាសមិទ្ធិលទ្ធភាពនៃទីផ្សារគណនាបុព្វលាភធានារ៉ាប់រងកម្ពុជា
- ផែនការអាជីវកម្មរយៈពេល ៥ (ប្រាំ) ឆ្នាំ
- សេចក្ដីព្រាងលក្ខន្តិកៈក្រុមហ៊ុនដែលនឹងបង្កើត
- ឯកសារថតចម្លងបញ្ជាក់អត្តសញ្ញាណរបស់ភាគទុនិកៈ
    - សម្រាប់ភាគទុនិកជារូបវន្តបុគ្គល ត្រូវផ្ដល់អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន
    - សម្រាប់ភាគទុនិកជានីតិបុគ្គល ត្រូវផ្ដល់ឯកសារគតិយុត្តអំពីអាជីវកម្ម និងអាសយដ្ឋានទីស្នាក់ការកណ្ដាល
- ឯកសារថតចម្លងបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល និងអភិបាល រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបស្ដីពីបទពិសោធការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រ
- ឯកសារបញ្ជាក់នាមករណ៍ក្រុមហ៊ុនបម្រុងទុក នៅក្រសួងពាណិជ្ជកម្ម
- ក្នុងករណីជាបុត្រសម្ព័ន្ធក្រុមហ៊ុន ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ត្រូវផ្ដល់ឯកសារបន្ថែមដូចខាងក្រោម៖
    - លិខិតអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើម ឱ្យប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ថតចម្លងបញ្ជាក់ដោយសារការី
    - សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម អនុញ្ញាតឱ្យប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

- ឯកសារអំពីប្រវត្តិសង្ខេប និងរចនាសម្ព័ន្ធនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ជាច្បាប់ថតចម្លង ដោយមានប្រថាប់ត្រាក្រុមហ៊ុន
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីចំណាត់ថ្នាក់របស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ដោយមានការវាយតម្លៃរបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ជាអន្តរជាតិ (ប្រសិនបើមាន)
- របាយការណ៍ស្តីពីលទ្ធផលត្រួតពិនិត្យចុងក្រោយរបស់និយ័តករនៃប្រទេសដើម ជាច្បាប់ថតចម្លង (ប្រសិនបើមាន)។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។ **ន.ធ.ក.** ផ្តល់លិខិតអនុញ្ញាតជាគោលការណ៍នេះ ជូនបុគ្គលស្នើសុំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងបន្តនីតិវិធីផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ១៤.-**

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រងជាក្រុមហ៊ុន ឬសាខាក្រុមហ៊ុនបរទេស និងបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- សាលាកប័ត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញនិងដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សា-ភិបាលឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល តាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា
- លិខិតអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីរចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រង ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន

- ឯកសារអំពីគណនីរបស់ក្រុមហ៊ុននៅធនាគារដែលបញ្ជាក់ចំនួនដើមទុនអប្បបរមាដែលមានចំនួន ៨០ ០០០ ០០០(ប៉ែតសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារបញ្ជាក់ចំនួនប្រាក់តម្កល់ធានាអាជីវកម្មដែលមានចំនួន ៤០ ០០០ ០០០(សែសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ៤ ០០០ ០០០ ០០០ (បួនបីលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ ជាច្បាប់ថតចម្លងដោយធ្វើនីត្យានុកូលកម្មពីអាជ្ញាធរដែនដី
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន ប្រវត្តិរូបសង្ខេបអំពីបទពិសោធការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រ
- លិខិតឬព្រឹត្តិបត្រថ្កោលទោសរបស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក ជាច្បាប់ដើមឬថតចម្លងបញ្ជាក់ដោយសារការី
- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ដោយភ្ជាប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិ រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន ប្រវត្តិរូបសង្ខេប និងវិញ្ញាបនបត្រវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់អាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១៥ ._**

ក្រុមហ៊ុនសវនកម្មដែលមានបំណងប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង។ ជាដំណាក់កាលដំបូងមុននឹងស្នើសុំអាជ្ញាបណ្ណ ក្រុមហ៊ុនត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង
- សាលាកប័ត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញនិងដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សា-ភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល តាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា

- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- ផែនការអាជីវកម្មរយៈពេល ៥ (ប្រាំ) ឆ្នាំ
- លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតអនុញ្ញាតប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន (ប្រសិនបើមានការតម្រូវដោយនិយ័តករតាមវិស័យ)។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។ **ន.ធ.ក.** ផ្តល់លិខិតអនុញ្ញាតជាគោលការណ៍នេះ ជូនបុគ្គលស្នើសុំសម្រាប់បន្តនីតិវិធីផ្សេងៗតាមការចាំបាច់។

**ប្រការ១៦.-**

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង ក្រុមហ៊ុនសវនកម្ម ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោមៈ

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- ឯកសារអំពីរចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រង ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីគណនីរបស់ក្រុមហ៊ុននៅធនាគារដែលបញ្ជាក់ចំនួនដើមទុនអប្បបរមាដែលមានចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារបញ្ជាក់ចំនួនប្រាក់តម្កល់ធានាអាជីវកម្មដែលមានចំនួន ៤០ ០០០ ០០០ (សែសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ៤ ០០០ ០០០ ០០០ (បួនប៊ីលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ដោយភ្ជាប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងគុណវុឌ្ឍិ រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន

ប្រវត្តិរូបសង្ខេប និងវិញ្ញាបនបត្រវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់អាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១៧ ._**

ក្រុមហ៊ុនដែលបានទទួលអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមគណនាបុព្វលាភធានារ៉ាប់រង មានសិទ្ធិផ្តល់សេវា ដូចខាងក្រោម៖

- សេវាអភិវឌ្ឍផលិតផលធានារ៉ាប់រង និងកំណត់អត្រាបុព្វលាភធានារ៉ាប់រង
- សេវាផ្តល់យោបល់លើការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល
- សេវាវាយតម្លៃនិងគណនាបុព្វលាភធានារ៉ាប់រងសម្រាប់គាំទ្រការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ
- សេវាផ្តល់យោបល់លើការគ្រប់គ្រងហានិភ័យ ដើមទុន កម្រិតសាធនភាព និងការធានារ៉ាប់រងបន្តរបស់ក្រុមហ៊ុនធានារ៉ាប់រង និងវាយតម្លៃនិងកំណត់ប្រាក់បម្រុងសម្រាប់ទូទាត់សំណងធានារ៉ាប់រង។

ក្នុងករណី ក្រុមហ៊ុនមានបំណងផ្តល់សេវាបន្ថែមក្រៅពីសេវាខាងលើ ក្រុមហ៊ុនត្រូវស្នើសុំការអនុញ្ញាតជាមុន មក **ន.ធ.ក.** ដោយភ្ជាប់ឯកសារតម្រូវតាមការកំណត់របស់ **ន.ធ.ក.**។

**ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០(ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១៨ ._**

ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង មក **ន.ធ.ក.** ឱ្យបានមុនរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ នៃកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ដែលត្រូវបន្តសុពលភាព ជាច្បាប់ដើម
- ផែនការអាជីវកម្មសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំបន្ទាប់ ដោយមានហត្ថលេខារបស់អគ្គនាយក

និងមានប្រថាប់ត្រាក្រុមហ៊ុន

- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ៤ ០០០ ០០០ ០០០(បួនបីលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ឆ្នាំចុងក្រោយ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ភ.** មានសិទ្ធិសម្រេចបន្តសុពលភាពអាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១៩ ._**

ក្នុងករណីក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេសមិនបានស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេសនោះត្រូវចាត់ទុកថាប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រងដោយគ្មានអាជ្ញាបណ្ណ។

**ប្រការ២០ ._**

អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស មានសុពលភាព ៥ (ប្រាំ) ឆ្នាំ។ អាជ្ញាបណ្ណនេះមិនអាចផ្ទេរ ឬលក់បានឡើយ។

**ប្រការ២១ ._**

ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ត្រូវបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រង ឱ្យទាន់ពេលវេលាមុនផុតសុពលភាពវិញ្ញាបនបត្រ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ធ.ភ.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រង។

## ផ្នែកទី៣

## ការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស

**ប្រការ២២.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង មក **ន.ធ.ក.** ដោយបំពេញលក្ខខណ្ឌគោលដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- មានដើមទុនអប្បបរមាចំនួន ២០០ ០០០ ០០០(ពីររយលាន) រៀល ក្នុងនោះប្រាក់តម្កល់ធានាអាជីវកម្មមានចំនួន ៤០ ០០០ ០០០(សែសិបលាន) រៀល
- មានការធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគ្រប់គ្រងសំណងធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០(ពីរប៊ីលាន) រៀល
- មានបុគ្គលវិជ្ជាជីវៈគ្រប់គ្រងសំណងធានារ៉ាប់រងយ៉ាងតិច ១ (មួយ) រូប ដែលមានបទពិសោធក្នុងការដោះស្រាយសំណងធានារ៉ាប់រង រយៈពេលយ៉ាងតិច ២(ពីរ) ឆ្នាំ និងមានជំនាញឯកទេសលើប្រភេទផលិតផលធានារ៉ាប់រងជាក់លាក់។

**ប្រការ២៣.-**

ជាដំណាក់កាលដំបូង មុននឹងស្នើសុំអាជ្ញាបណ្ណ បុគ្គលត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- ឯកសារអំពីការសិក្សាសមិទ្ធលទ្ធភាពនៃទីផ្សារគ្រប់គ្រងសំណងធានារ៉ាប់រងកម្ពុជា
- ផែនការអាជីវកម្មរយៈពេល ៥ (ប្រាំ) ឆ្នាំ
- សេចក្តីព្រាងលក្ខន្តិកៈក្រុមហ៊ុនដែលនឹងបង្កើត
- ឯកសារថតចម្លងបញ្ជាក់អត្តសញ្ញាណរបស់ភាគទុនិកៈ
  - សម្រាប់ភាគទុនិកជារូបវន្តបុគ្គល ត្រូវផ្តល់អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន
  - សម្រាប់ភាគទុនិកជានីតិបុគ្គល ត្រូវផ្តល់ឯកសារគតិយុត្តអំពីអាជីវកម្ម និងអាសយដ្ឋានទីស្នាក់ការកណ្តាល
- ឯកសារថតចម្លងបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល និងអភិបាល រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបស្តីពីបទពិសោធការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រ

- ឯកសារបញ្ជាក់នាមករណ៍ក្រុមហ៊ុនបម្រុងទុក នៅក្រសួងពាណិជ្ជកម្ម
- ក្នុងករណីជាបុត្រសម្ព័ន្ធក្រុមហ៊ុន ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវផ្តល់ឯកសារបន្ថែមដូចខាងក្រោម៖
  - លិខិតអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមឱ្យប្រកបអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ថតចម្លងបញ្ជាក់ដោយសារការី (ប្រសិនបើមាន)
  - សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម អនុញ្ញាតឱ្យប្រកបអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - ឯកសារអំពីប្រវត្តិសង្ខេប និងរចនាសម្ព័ន្ធនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើមសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - ឯកសារអំពីចំណាត់ថ្នាក់របស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ដោយមានការវាយតម្លៃរបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ជាអន្តរជាតិ (ប្រសិនបើមាន)
  - របាយការណ៍ស្តីពីលទ្ធផលត្រួតពិនិត្យចុងក្រោយរបស់និយ័តករនៃប្រទេសដើម ជាច្បាប់ថតចម្លង (ប្រសិនបើមាន)។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។ **ន.ធ.ក.** ផ្តល់លិខិតអនុញ្ញាតជាគោលការណ៍នេះ ជូនបុគ្គលស្នើសុំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងបន្តនីតិវិធីផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ២៤.-**

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រង ជាក្រុមហ៊ុន ឬសាខាក្រុមហ៊ុនបរទេស និងបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល

- សាលាកប័ត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញនិងដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល តាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា
- លិខិតអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីរចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រង ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីស្តង់ដារប្រតិបត្តិក្នុងការគ្រប់គ្រងសំណងធានារ៉ាប់រង
- ឯកសារអំពីគណនីរបស់ក្រុមហ៊ុននៅធនាគារដែលបញ្ជាក់ចំនួនដើមទុនអប្បបរមាដែលមានចំនួន ២០០ ០០០ ០០០(ពីររយលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារបញ្ជាក់ចំនួនប្រាក់តម្កល់ធានាអាជីវកម្មដែលមានចំនួន ៤០ ០០០ ០០០(សែសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគ្រប់គ្រងសំណងធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០(ពីរប៊ីលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ ជាច្បាប់ថតចម្លងដោយធ្វើនីត្យានុកូលកម្មពីអាជ្ញាធរដែនដី
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបអំពីបទពិសោធការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រ
- លិខិតឬព្រឹត្តិបត្រថ្កោលទោសរបស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក ជាច្បាប់ដើមឬថតចម្លងបញ្ជាក់ដោយសារការី
- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈគ្រប់គ្រងសំណងធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរួមមាន អត្តសញ្ញាណបណ្ណ ឬលិខិត ឆ្លងដែន ប្រវត្តិរូបសង្ខេប និងវិញ្ញាបនបត្រវិជ្ជាជីវៈ ឬលិខិតបញ្ជាក់អំពីបទពិសោធក្នុងការដោះស្រាយ សំណងធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ឆ.ក.** មានសិទ្ធិសម្រេចផ្តល់អាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ២៥ .-**

ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង មក **ន.ឆ.ក.** ឱ្យបានមុនរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ នៃកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ដែលត្រូវបន្តសុពលភាព ជាច្បាប់ដើម
- ផែនការអាជីវកម្មសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំបន្ទាប់ ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគ្រប់គ្រងសំណងធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០(ពីរប៊ីលាន) រៀល ជាច្បាប់ថតចម្លង ដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ឆ្នាំចុងក្រោយ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ឆ.ក.** មានសិទ្ធិសម្រេចបន្តសុពលភាពអាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ២៦ .-**

ក្នុងករណីក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស មិនបានស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសនោះ ត្រូវចាត់ទុកថាប្រកបអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រងដោយគ្មានអាជ្ញាបណ្ណ។

**ប្រការ២៧.-**

អាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ជាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស មានសុពលភាព ៥ (ប្រាំ) ឆ្នាំ។ អាជ្ញាបណ្ណនេះមិនអាចផ្ទេរ ឬលក់បានឡើយ។

**ប្រការ២៨.-**

ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគ្រប់គ្រងសំណងធានារ៉ាប់រង ឱ្យទាន់ពេលវេលាមុនផុតសុពលភាពវិញ្ញាបនបត្រ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈគ្រប់គ្រងសំណងធានារ៉ាប់រង។

## ជំពូកទី៤

## ការតម្រូវផ្សេងៗ

**ប្រការ២៩.-**

ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានអាជ្ញាបណ្ណអាជីវកម្ម ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស មិនបានចាប់ផ្ដើមប្រតិបត្តិការអាជីវកម្មអាជ្ញាបណ្ណអាជីវកម្មរបស់ក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស នឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ លើកលែងតែមានការអនុញ្ញាតពី **ន.ធ.ក.**។

**ប្រការ៣០.-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ចំពោះការតែងតាំងឬផ្លាស់ប្ដូរបុគ្គលវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រង គណនាបុព្វលាភធានារ៉ាប់រង ឬគ្រប់គ្រងសំណងធានារ៉ាប់រង តាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតតែងតាំងឬផ្លាស់ប្ដូរបុគ្គលវិជ្ជាជីវៈ
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រង ឬគណនាបុព្វលាភធានារ៉ាប់រង ឬគ្រប់គ្រងសំណងធានារ៉ាប់រង រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន ប្រវត្តិរូបសង្ខេប និងវិញ្ញាបនបត្រវិជ្ជាជីវៈ ឬលិខិតបញ្ជាក់អំពីបទពិសោធការងារវាយតម្លៃហានិភ័យធានារ៉ាប់រង ឬគណនាបុព្វលាភធានារ៉ាប់រង ឬគ្រប់គ្រងសំណងធានារ៉ាប់រង។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០(ម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៣១ ..**

រាល់ការផ្លាស់ប្តូរព័ត៌មានអំពីក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស មានជាអាទិ៍ នាមករណ៍ក្រុមហ៊ុន ម៉ាក ទីតាំងអាជីវកម្ម គេហទំព័រក្រុមហ៊ុន ម្ចាស់ភាគហ៊ុន សមាសភាពក្រុមប្រឹក្សាភិបាល អគ្គនាយក ឬការកែប្រែលក្ខខណ្ឌណាមួយក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ធ.ក.**។

**ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០(ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

ឯកសារតម្រូវសម្រាប់ស្នើសុំការអនុញ្ញាតផ្លាស់ប្តូរព័ត៌មានអំពីក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវកំណត់ដោយ **ន.ធ.ក.**។

**ប្រការ៣២ ..**

ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ដែលមានបំណងផ្តល់សេវាវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងបន្ថែមលើសេវាដែលបានអនុញ្ញាតក្នុងប្រការ ១៧ នៃប្រកាសនេះ ត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតផ្តល់សេវាវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងបន្ថែម
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារពិពណ៌នាអំពីសេវាវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងបន្ថែម ដោយមានហត្ថលេខារបស់អគ្គនាយកនិងមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ភ.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៣៣ .-**

ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ដែលមានបំណងផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងលើប្រភេទផលិតផលធានារ៉ាប់រងណាមួយបន្ថែម ត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ភ.** ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងលើប្រភេទផលិតផលធានារ៉ាប់រងបន្ថែម
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារពិពណ៌នាអំពីសេវាគ្រប់គ្រងសំណងធានារ៉ាប់រងលើប្រភេទផលិតផលធានារ៉ាប់រងបន្ថែម ដោយមានហត្ថលេខារបស់អគ្គនាយកនិងមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈគ្រប់គ្រងសំណងធានារ៉ាប់រងដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងគុណវុឌ្ឍិ រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន ប្រវត្តិរូបសង្ខេប និងវិញ្ញាបនបត្រវិជ្ជាជីវៈឬលិខិតបញ្ជាក់អំពីបទពិសោធការងារដោះស្រាយសំណងធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ភ.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៣៤ .-**

ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ដែលមានបំណងចាប់ដៃគូ ឬផ្លាស់ប្តូរដៃគូផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ភ.** ដោយភ្ជាប់ឯកសារតម្រូវតាមករណីដូចខាងក្រោម៖

ក. ចំពោះការស្នើសុំការអនុញ្ញាតចាប់ដៃគូផ្តល់សេវាជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត
   - លិខិតស្នើសុំការអនុញ្ញាតចាប់ដៃគូផ្តល់សេវាជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត
   - បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
   - សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
   - សេចក្តីព្រាងកិច្ចព្រមព្រៀងផ្តល់សេវាជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត។

ខ. ចំពោះការស្នើសុំការអនុញ្ញាតផ្លាស់ប្តូរដៃគូផ្តល់សេវាជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត

- លិខិតស្នើសុំការអនុញ្ញាតផ្លាស់ប្តូរដៃគូផ្តល់សេវាជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតបញ្ជាក់ការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត
- សេចក្តីព្រាងកិច្ចព្រមព្រៀងជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀតដែលជាដៃគូថ្មី។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ភ.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៣៥ _**

រាល់ការចាប់ដៃគូ ឬការផ្លាស់ប្តូរដៃគូ ឬការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាគ្រប់គ្រងសំណាងធានារ៉ាប់រង ជាមួយក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនគ្រប់គ្រងសំណាងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណាងធានារ៉ាប់រងបរទេស ត្រូវជូនដំណឹងមក **ន.ធ.ភ.** ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ ក្រោយការចាប់ដៃគូ ឬការផ្លាស់ប្តូរដៃគូ ឬការបញ្ឈប់ការចាប់ដៃគូ ដោយត្រូវភ្ជាប់ឯកសារតម្រូវតាមករណីដូចខាងក្រោម៖

ក. ចំពោះការជូនដំណឹងអំពីការចាប់ដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង
- លិខិតជូនដំណឹងអំពីការចាប់ដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- កិច្ចព្រមព្រៀងសេវាគ្រប់គ្រងសំណាងធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង។

ខ. ចំពោះការជូនដំណឹងអំពីការផ្លាស់ប្តូរដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង
- លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតបញ្ជាក់ការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង
- កិច្ចព្រមព្រៀងសេវាគ្រប់គ្រងសំណាងធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលជាដៃគូថ្មី។

គ. ចំពោះការជូនដំណឹងអំពីការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង
- លិខិតជូនដំណឹងអំពីការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង ដោយបញ្ជាក់មូលហេតុនៃការបញ្ឈប់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតបញ្ជាក់ពីការបញ្ឈប់ការចាប់ដៃគូផ្តល់សេវា ដោយមានហត្ថលេខារបស់ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនគ្រប់គ្រងសំណាងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណាងធានារ៉ាប់រងបរទេស។

**ប្រការ៣៦ ._**

រាល់ការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ ក្រោយបញ្ឈប់ការចាប់ដៃគូ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតជូនដំណឹងអំពីការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតបញ្ជាក់ពីការបញ្ឈប់ការចាប់ដៃគូផ្តល់សេវា ដោយមានហត្ថលេខារបស់ភាគីតំណាងក្រុមហ៊ុនធានារ៉ាប់រង ឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត និងក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស។

**ប្រការ៣៧ ._**

រាល់ការផ្លាស់ប្តូរ ឬកែប្រែឯកសារអំពីស្តង់ដារប្រតិបត្តិក្នុងការគ្រប់គ្រងសំណងធានារ៉ាប់រង ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ ក្រោយការផ្លាស់ប្តូរ ឬកែប្រែ ដោយត្រូវភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរ ឬកែប្រែឯកសារអំពីស្តង់ដារប្រតិបត្តិក្នុងការគ្រប់គ្រងសំណងធានារ៉ាប់រង
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលជាច្បាប់ដើម ឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីស្តង់ដារប្រតិបត្តិក្នុងការគ្រប់គ្រងសំណងធានារ៉ាប់រងដែលបានផ្លាស់ប្តូរ ឬកែប្រែដោយមានហត្ថលេខារបស់អគ្គនាយកនិងមានប្រថាប់ត្រាក្រុមហ៊ុន។

## ជំពូកទី៥

## កម្រៃសេវារដ្ឋបាល និងកម្រៃអាជ្ញាបណ្ណ

**ប្រការ៣៨ ._**

រាល់កម្រៃអាជ្ញាបណ្ណ កម្រៃសេវារដ្ឋបាល និងប្រាក់ផាកពិន័យ ត្រូវបង់ចូលគណនីរបស់ **ន.ធ.ក.**។

### ផ្នែកទី១

### កម្រៃសេវារដ្ឋបាល

**ប្រការ៣៩.-**

បុគ្គលស្នើសុំ ត្រូវបង់កម្រៃសេវារដ្ឋបាល ដូចខាងក្រោម៖

- សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រង អាជីវកម្មគណនាបុព្វលាភធានារ៉ាប់រង ឬអាជីវកម្មគ្រប់គ្រងសំណងធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ចំនួន ៥០០ ០០០(ប្រាំរយពាន់) រៀល។
- សេវាពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រង ចំនួន ៥០០ ០០០(ប្រាំរយពាន់) រៀល។

**ប្រការ៤០.-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាត បន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មសេវាគាំទ្រអាជីវកម្មធានារ៉ាប់រងចំនួន ៥០០ ០០០(ប្រាំរយពាន់) រៀល។

**ប្រការ៤១.-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រងគណនាបុព្វលាភធានារ៉ាប់រង ឬគ្រប់គ្រងសំណងធានារ៉ាប់រង ចំនួន ១ ០០០ ០០០(មួយលាន) រៀល ក្នុង ១(មួយ) លើក។

**ប្រការ៤២.-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតផ្លាស់ប្តូរព័ត៌មានណាមួយអំពីក្រុមហ៊ុនដូចមានចែងក្នុងប្រការ ៣១ចំនួន ៨០០ ០០០(ប្រាំបីរយពាន់) រៀល។

**ប្រការ៤៣.-**

ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ត្រូវបង់

កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតផ្តល់សេវាវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងបន្ថែមមួយ ចំនួន ៨០០ ០០០(ប្រាំបីរយពាន់) រៀល។

**ប្រការ៤៤.-**

ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងលើប្រភេទផលិតផលធានារ៉ាប់រងណាមួយបន្ថែមចំនួន ៨០០ ០០០(ប្រាំបីរយពាន់) រៀល។

**ប្រការ៤៥.-**

ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតចាប់ដៃគូ ឬផ្លាស់ប្តូរដៃគូផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ចំនួន ៨០០ ០០០(ប្រាំបីរយពាន់) រៀល ក្នុងមួយដៃគូ។

**ប្រការ៤៦.-**

កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារអនុលោមតាមខ្លឹមសារនៃប្រកាសនេះ មិនត្រូវប្រគល់ឱ្យបុគ្គលស្នើសុំ ឬក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសវិញឡើយ ទោះបីជាការស្នើសុំត្រូវបដិសេធក៏ដោយ។

## ផ្នែកទី២

## កម្រៃអាជ្ញាបណ្ណ

**ប្រការ៤៧.-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃអាជ្ញាបណ្ណនៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនិងនៅរៀងរាល់ពេលដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ចំនួន ៥ ០០០ ០០០(ប្រាំលាន) រៀល។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ៤៨.-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមិនអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលវិធានការរដ្ឋបាលពី **ន.ធ.ក.** ដូចខាងក្រោម៖

- ការព្រមាន
- ការដឹកនាំកែតម្រង់
- ការដាក់កំហិតលើសកម្មភាពអាជីវកម្ម
- ការដាក់កំហិតលើអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត
- ការដកហូតអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត។

**ប្រការ៤៩.-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ៥០០ ០០០ (ប្រាំរយពាន់) រៀល ទៅ ២៥ ០០០ ០០០(ម្ភៃប្រាំលាន) រៀល ដោយ **ន.ធ.ក.** និងត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណជាបន្ទាន់ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមិនស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណឱ្យបានមុនរយៈពេល ៣០(សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ នៃកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដូចមានចែងក្នុងប្រការ៨ ប្រការ១៨ និងប្រការ២៥ នៃប្រកាសនេះ។

**ប្រការ៥០.-**

ត្រូវទទួលទោសតាមច្បាប់ស្តីពីការធានារ៉ាប់រង និងត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណជាបន្ទាន់ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណនោះ ចំពោះក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមិនបានស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដូចមានចែងក្នុងប្រការ៩ ប្រការ១៩ និងប្រការ២៦ នៃប្រកាសនេះ។

**ប្រការ៥១.-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក** និងត្រូវបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈនិងជូនដំណឹងមក **ន.ធ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមិនបានបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈទាន់ពេលវេលា និងមិនបានជូនដំណឹងមក **ន.ធ.ក.** តាមកាលបរិច្ឆេទកំណត់ ដូចមានចែងក្នុងប្រការ១១ ប្រការ២១ និងប្រការ២៨ នៃប្រកាសនេះ។

**ប្រការ៥២.-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ធ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលតែងតាំងឬផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រង គណនាបុព្វលាភធានារ៉ាប់រង ឬគ្រប់គ្រងសំណងធានារ៉ាប់រង ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ដូចមានចែងក្នុងប្រការ៣០ នៃប្រកាសនេះ។

**ប្រការ៥៣.-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** និងត្រូវស្នើសុំការអនុញ្ញាត មក **ន.ធ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលបានផ្លាស់ប្តូរព័ត៌មានឬលក្ខខណ្ឌណាមួយក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន

ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ឆ.ក.** ដូចមានចែងក្នុងប្រការ៣១ នៃប្រកាសនេះ។

**ប្រការ៥៤ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ឆ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ឆ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេសទាំងឡាយណា ដែលផ្តល់សេវាវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រងបន្ថែម ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ឆ.ក.** ដូចមានចែងក្នុងប្រការ៣២ នៃប្រកាសនេះ។

**ប្រការ៥៥ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ឆ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ឆ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងលើប្រភេទផលិតផលធានារ៉ាប់រងណាមួយបន្ថែម ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ឆ.ក.** ដូចមានចែងក្នុងប្រការ៣៣ នៃប្រកាសនេះ។

**ប្រការ៥៦ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ឆ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ឆ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលចាប់ដៃគូ ឬផ្លាស់ប្តូរដៃគូផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ឆ.ក.** ដូចមានចែងក្នុងប្រការ៣៤ នៃប្រកាសនេះ។

**ប្រការ៥៧ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន) រៀល ដោយ **ន.ឆ.ក.** ចំពោះក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែល

ចាប់ដៃគូ ឬផ្លាស់ប្តូរដៃគូ ឬបញ្ឈប់ការចាប់ដៃគូផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង ដោយមិនបានជូនដំណឹងមក **ន.ធ.ក.** តាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងប្រការ៣៥ នៃប្រកាសនេះ។

**ប្រការ៥៨ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលបញ្ឈប់ការចាប់ដៃគូផ្តល់សេវាគ្រប់គ្រងសំណងធានារ៉ាប់រងជាមួយនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដោយមិនបានជូនដំណឹងមក **ន.ធ.ក.** តាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងប្រការ៣៦ នៃប្រកាសនេះ។

**ប្រការ៥៩ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រង ឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលផ្លាស់ប្តូរ ឬកែប្រែឯកសារអំពីស្តង់ដារប្រតិបត្តិក្នុងការគ្រប់គ្រងសំណងធានារ៉ាប់រង ដោយមិនបានជូនដំណឹងមក **ន.ធ.ក.** តាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងប្រការ៣៧ នៃប្រកាសនេះ។

**ប្រការ៦០ .-**

ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងឬសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេស ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងឬសាខាក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រងបរទេស ក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងឬសាខាក្រុមហ៊ុនគ្រប់គ្រងសំណងធានារ៉ាប់រងបរទេសទាំងឡាយណា ដែលធ្លាប់ទទួលការផាកពិន័យអន្តរការណ៍ម្តងហើយ ប៉ុន្តែនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ក្រុមហ៊ុនត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនទ្វេដងនៃទឹកប្រាក់ផាកពិន័យលើកមុន និង/ឬត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤៨ នៃប្រកាសនេះ។

**ប្រការ៦១ .-**

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) និងជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

**ប្រការ៦២ .-**

បែបបទ និងនីតិវិធីនៃការចាត់វិធានការរដ្ឋបាល និងការផាកពិន័យដូចមានចែកក្នុងជំពូកនេះ ត្រូវកំណត់ដោយ **ន.ធ.ក.**។

**ប្រការ៦៣ .-**

បុគ្គលដែលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់និយ័តករ ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រង។

**ប្រការ៦៤ .-**

វិធានការរដ្ឋបាលនិងការផាកពិន័យដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**ប្រការ៦៥ .-**

អាជ្ញាបណ្ណដែលបានផ្តល់ជូនក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងទាំងអស់ អនុលោមតាមប្រកាសលេខ ៨៦៥ សហវ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការចេញអាជ្ញាបណ្ណធានារ៉ាប់រងជូនភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង និង/ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវបន្តសុពលភាពរហូតដល់ផុតកាលកំណត់នៃអាជ្ញាបណ្ណ ទោះជាប្រកាសនេះចាប់ផ្តើមអនុវត្តក៏ដោយ។

**ប្រការ៦៦ .-**

ក្នុងអំឡុងពេល ១២ (ដប់ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទអនុវត្តប្រកាសនេះ ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង និងសាខាក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងបរទេសទាំងឡាយដែលកំពុងប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញដើមទុនអប្បបរមា និងត្រូវបង្កើនទឹកប្រាក់ធានារ៉ាប់រងចំពោះការធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រងឱ្យគ្រប់ចំនួនដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ៦៧ .-**

អគ្គនាយកនៃ **ន.ធ.ក.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង និងប្រកាសនេះដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ៦៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦៩.-**

អគ្គនាយកនៃ **ន.ធ.ភ.** ប្រធាននាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណនិងកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋានស្ថិតក្រោមចំណុះ **ន.ធ.ភ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៦ រោច ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- និយ័តករគណនេយ្យនិងសវនកម្ម
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សា-អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

  “ដើម្បីជូនជ្រាប”
- ដូចប្រការ៦៩

  “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ